
Reading Book

ពិភពរឿងនិទាន

The World of Stories

ចោរចិត្តឆ្ងា


Chor Chitchea (Generous Thief)



M.81

សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the Source of Knowledge



មានរឿងព្រេងមួយដំណាលថា កាលណោះមានក្មេងប្រុសម្នាក់
នៅជាមួយឪពុកម្តាយ។ ដោយសារតែក្មេងប្រុសនេះចូលចិត្តលួចគេ
អ្នកស្រុកក៏ហៅគេថា **អាចោរចិត្តជា**។ លុះក្មេងនោះចម្រើនវ័យធំ
ឡើងឪពុកក៏ស្លាប់ចោលទៅនៅតែម្តាយ។ ចៅនោះមិនគិតធ្វើការ
រកស៊ីអ្វីទេឱ្យតែដល់វេលាយប់កាលណា **ចោរចិត្តជា** ដើរលួចទ្រព្យ
សម្បត្តិអ្នកស្រុកទាំងពួង។ មាតាទូន្មានប្រដៅដូចម្តេចក៏មិនព្រមធ្វើ
តាម ទើបម្តាយយកកូនទៅនៅឯវត្តរៀនអក្សរ។ ចៅនោះក៏មិនខំ
រៀនសូត្រទៀត ប្រព្រឹត្តិតែអំពើលួចទ្រព្យគេយកមកចិញ្ចឹមមាតានិង
អាត្មា។ គ្រូរំលឹកប្រដៅដូចម្តេចក៏មិនព្រមស្តាប់។


A tale is narrated that once a time there lived a boy with his father. Since the boy was keen on theft, the villagers called him Chor Chitchea (Generous Thief). When the boy grew up, his father passed away, leaving him to live with his mother. The thief never thought of making his living. When the sky was dark, he came out to steal the villagers' belongings. His mother always gave him advice, but he never obeyed what she had told, therefore she decided to send him to study the language at a pagoda. This young fellow, however, did not study hard, he stole belongings of the other people to feed his mother and himself and never obeyed his teacher's advice.

ថ្ងៃមួយស្តេចក្នុងនគរនោះ ទ្រង់ចេញប្រថាប់ចុងព្រះរាជរោង ឱ្យ
សេនាបតីនាម៉ឺនសព្វមុខមន្ត្រីចូលគាល់ ទ្រង់មានព្រះរាជឱង្ការថា
"មានខេត្តមួយនៅទំនេរពុំទាន់មានឈ្មោះណាទៅឈរក្សានៅ
ឡើយ បើអ្នកណាយកប្រាក់៤០កហាបណៈមកដាក់ឃ្លាំង យើងនឹង
ឱ្យទៅឈរជាចៅហ្វាយស្រុករក្សាខេត្តនោះ។ បន្ទាប់មកស្តេចក៏
យាងចូលក្នុងព្រះបរមរាជវាំងវិញ។ គ្រានោះមានមន្ត្រីតូចម្នាក់វិល
មកផ្ទះដេកកើតទុក្ខចង់ធ្វើជាចៅហ្វាយស្រុកនោះណាស់។

One day the king of that kingdom went to the royal hall where he ordered all officials to meet him. "There is a vacancy for the position of a district governor," the king said to all officials. "If anyone pays 40 Kahapanaks for the royal bank, I'll offer him that position." Then the king went back to the royal palace. At that moment, when a low ranking official arrived home, he was very anxious to hold that position.




លុះដល់វេលាយប់ចូលដំណេក ប្តីនិយាយនឹងភរិយាថា "អូនអើយ! ឥឡូវនេះស្តេចមានព្រះរាជបន្ទូលថា បើឈ្មោះណាមានប្រាក់៤០ កហាបណៈថ្វាយព្រះអង្គដាក់ឃ្លាំង ទ្រង់នឹងឱ្យធ្វើជាចៅហ្វាយស្រុក រក្សាខេត្តមួយដែលនៅទំនេរ"។



ភរិយាឆ្លើយថា "ឱអ្នកអើយ! ចិត្តខ្ញុំចង់ឱ្យអ្នកធ្វើចៅហ្វាយស្រុកណាស់ តែសព្វថ្ងៃយើងក្រីក្រពេកធ្វើម៉េចនឹងបានប្រាក់ថ្វាយស្តេចទៅ"។ និយាយហើយក៏នាំគ្នាបន់ទេវតាថា "សូមទេវតាជួយខ្ញុំឱ្យបានប្រាក់៤០កហាបណៈថ្វាយស្តេច ខ្ញុំនឹងបានធ្វើជាចៅហ្វាយស្រុកនៅគ្រានេះ"។

While sleeping, the official talked to his wife, "My dear! The king said that if anyone had paid 40 kahapanaks for the royal bank, he'd allow him to hold the position of a governor of the district." His wife replied, "I really want you to have this position, but we're very poor. How can we have this sum for the king?" Then both husband and wife prayed to Devata, "May Devata give me 40 kahapanaks so that I can become the head of a district!"





ពេលនោះ **ចោរចិត្តថា** ដើរលួចគេហើយមកអង្គុយក្រោមផ្ទះមន្ត្រី
នោះបានស្តាប់ឮដូច្នោះមានចិត្តអាណិតក៏យកប្រាក់៤០កហាបណៈពីផ្ទះ
ខ្លួនវេចនឹងកំណាត់សំពត់ជាតីមកលូកដៃតាមជញ្ជាំងទៅទុកឱ្យ
មន្ត្រីនោះរួចត្រឡប់ទៅវិញ។ លុះភ្លឺច្បាស់មន្ត្រីនោះភ្ញាក់ឡើង
ក្រឡេកឃើញបង្គេចសំពត់ជាតីក៏ចាប់លើកស្រាយមើលឃើញប្រាក់
៤០កហាបណៈអរណាស់ក៏ប្រាប់ប្រពន្ធថា "យើងបានប្រាក់៤០
កហាបណៈហើយគឺជាប្រាក់ដែលទេវតាប្រគល់ឱ្យយើង"។ ប្រពន្ធ
ស្ទុះមកមើលឃើញច្បាស់ក៏មានចិត្តត្រេកអរពន់ពេក។

At the moment of coming back from stealing, the generous thief sat under the house of that official and heard their prayer; the thief felt pity for the official, so he went to get 40 kahapanaks from his home and wrapped it in red cotton cloth. The thief put his arm through the wall to leave the package for the official and returned home. The next morning, the official got up and found the red package. Unwrapping the package, he saw 40 kahapanaks. To his surprise, he told his wife, "We now get 40 kahapanaks from Devata." His wife suddenly and hurriedly approached to see with her own eye. When she discovered that it was real money, she was very cheerful.


លុះដល់ថ្ងៃរសៀលមន្ត្រីនោះយកប្រាក់៤០កហាបណៈទៅថ្វាយស្តេច ដាក់ឃ្លាំង។ ព្រះរាជាក៏តាំងមន្ត្រីនោះឱ្យធ្វើជាចៅហ្វាយស្រុករក្សាខេត្តនោះតទៅ។ ឯ **ចោរចិត្តជា** កាលបើបានដឹងថា មន្ត្រីនោះបានធ្វើជាចៅហ្វាយស្រុកហើយក៏ដើរស្វែងរកលួចអ្នកស្រុកក្នុងខេត្តនោះ



ធ្វើដំណើរឱ្យគេចាប់ខ្លួនបាន។ ម្ចាស់ទ្រព្យនាំ **ចោរចិត្តជា** នោះទៅជូនចៅហ្វាយស្រុកៗបង្គាប់មេគុកឱ្យដាក់ច្រវាក់ឃុំទុកក្រោមផ្ទះលោក។ ដល់វេលាយប់ស្ងាត់ **ចោរចិត្តជា** និយាយតែម្នាក់ឯងថា "ឱព្រះអើយ! ហេតុតែឯងមានចិត្តអាណិតគេៗចង់ធ្វើចៅហ្វាយស្រុក ខ្លួនឯងខំយកប្រាក់៤០កហាបណៈវេចនឹងកំណាត់ជាតីយកមកឱ្យគេទាំងយប់ តទ្បូវគេបានធ្វើចៅហ្វាយស្រុកហើយគេមិនមេត្តាដល់ឯងបន្តិចសោះ គេបែរជាដាក់ច្រវាក់ឃុំឯងទុកឱ្យវេទនា"។ **ចោរចិត្តជា** និយាយតែពាក្យដដែលៗម្នាក់ឯងជាច្រើនដង។

In the afternoon, the official took 40 kahapanaks to the king to put in the royal bank. The king then assigned him the head of that district. When the generous thief was aware that the low ranking official was appointed as the head of the district, he stole the properties of the people in that district and let the owner capture him. The owner took the generous thief to the governor's house. The governor ordered a prison leader to chain the thief and detained him under his house. In the quiet night, the generous thief talked to himself, "My God! I felt pity for him because he wanted to be the governor, so at nighttime I myself left him 40 kahapanaks in red cotton cloth. He is now a leader of the district, but unkind to me. I am sadly detained by that man." And the generous thief kept saying his words.

ឯចៅហ្វាយស្រុក និងប្រពន្ធបានឮចោរនិយាយដូច្នោះ ក៏ពិភាក្សាគ្នាថា "ចោរនិយាយនេះដូចរឿងយើងណាស់ យើងគួរតែចុះទៅសួរវាមើល៍"។ ចៅហ្វាយស្រុកចុះពីផ្ទះសួរ **ចោរចិត្តជា** ថា "យើងឮឯងនិយាយអី យើងដូចជាស្តាប់បានខ្លះៗ ចូរឯងនិយាយម្តងទៀតទៅមើល៍"។



ចោរចិត្តជា ប្រាប់ថា "ខ្លួនខ្ញុំនេះជាមនុស្សប្រព្រឹត្តចោរកម្មដើរលួចតែទ្រព្យ គេរាល់យប់យកមកចិញ្ចឹមជីវិត កាលពីលោកនៅជាមន្ត្រីតូចពុំទាន់បានធ្វើជាចៅហ្វាយស្រុក វេលាយប់មួយនោះខ្ញុំដើរលួចគេហើយមកអង្គុយក្រោមផ្ទះលោក ឮលោកនិយាយនឹងប្រពន្ធថា ពួកលោកចង់បានប្រាក់៤០កហាបណៈថ្វាយស្តេច ព្រោះចង់ធ្វើជាចៅហ្វាយស្រុក។ ខ្ញុំឮដូច្នេះមានចិត្តអាណិតលោកក៏ទៅយកប្រាក់៤០កហាបណៈពីផ្ទះវេចនឹងកំណាត់សំពត់ជាតីមកដាក់ជិតក្បាលដំណេកទុកជូនលោក ហើយខ្ញុំក៏ត្រឡប់ទៅវិញ។ ក្រោយមកខ្ញុំឮគេនិយាយថា លោកបានធ្វើចៅហ្វាយស្រុកខ្ញុំក៏មកលួចគេនៅក្នុងខេត្តនេះឱ្យគេចាប់ខ្លួនខ្ញុំ គេក៏នាំខ្ញុំមកជូនលោកៗក៏ដាក់ទោសខ្ញុំមិនប្រណី"។

When the district leader and his wife heard this saying, they consulted with each other. "The thief's words are similar to our story," said one of them. "Let's go down to ask him." The district governor went down to ask the thief, "We heard what you have said, we have understood some words. Say it again, please." The generous thief replied,

"I have always stolen things from people every night to earn a living. When you were a low ranking official, not yet a district leader, one night, after returning from stealing, I sat under your house hearing you tell your wife that you needed 40 kahapanaks for the king, since you wanted to be the district leader in a province. I felt pity for you, so I went home to bring 40 kahapanaks wrapped in red cotton cloth. I put it at your head side and then returned home. When I heard that you became a district leader, I came to steal the people's belongings in your district in order to be captured. When taken to you, I was severely punished."



ចៅហ្វាយស្រុកស្តាប់ហើយក៏ជឿជាក់ហើយនិយាយថា "ឱសម្លាញ់អើយ! នេះជារឿងពិតដែលខ្ញុំបានធ្វើចៅហ្វាយស្រុកក៏ព្រោះតែឯងជួយខ្ញុំ តទ្បូវឯងឈប់ពិបាកចិត្តទៅ ព្រឹកនេះខ្ញុំនឹងលែងឯងឱ្យរួចផុតពីទោស ហើយឯងនឹងខ្ញុំគឺជាសម្លាញ់នឹងគ្នាតទៅ"។ ចៅហ្វាយស្រុកសួរថា "ឯងឈ្មោះអី?"។ បុរសនោះជម្រាបថា "ខ្ញុំឈ្មោះ **ចោរចិត្តជា**"។

Listening to the thief, the district leader believed what he said. "Pal," the governor replied, "It's true. I could become a district leader because of your assistance. Don't worry! I'll free you tomorrow. And we'll be friends."

The district leader asked, "What's your name?"

"My name's Chor Chitchea," the thief replied.



លុះភ្លឺច្បាស់ចៅហ្វាយស្រុកក៏ដោះលែង **ចោរចិត្តជា** ហើយនិយាយថា "សម្លាញ់! ខ្ញុំនឹងចិញ្ចឹមឯងពីថ្ងៃនេះតទៅ តែឯងកុំលួចគេទៀតអី"។ **ចោរចិត្តជា** ឆ្លើយថា "រឿងលួចនោះខ្ញុំមិនទាន់ឈប់ទេ ខ្ញុំគ្រាន់តែលួចប្រាក់បន្តិចបន្តួចយកទៅចិញ្ចឹមមាតាមេម៉ាយតែប៉ុណ្ណោះ"។ ចៅហ្វាយស្រុកក៏ឱ្យប្រាក់៣០កហាបណៈផ្ញើទៅឱ្យមាតា តែ **ចោរចិត្តជា** ប្រកែកមិនព្រមយក។ ចៅហ្វាយស្រុកសួរថា "ផ្ទះសម្លាញ់ឯងនៅឯណា?"។ **ចោរចិត្តជា** ប្រាប់ថា "ផ្ទះខ្ញុំនៅទីនោះ" ហើយលាចៅហ្វាយស្រុកទៅផ្ទះវិញ។

When the sun was rising, the governor released Chor Chitchea and said, "Pal! I'll raise you, so stop stealing from people."

"I can't stop," refused the thief, "I steal only little money to raise my widowed mother." The leader gave Chor Chitchea 30 kahapanaks for his mother, but he declined the offer. "Where's your house?" asked the governor.

"It's over there," the thief replied. Then he requested to return home.




គ្រានោះមានលោកយមរាជ និងមន្ត្រីតូចម្នាក់កើតសេចក្តីវិវាទទាស់ទែងគ្នាជាយូរខែ ហើយមន្ត្រីតូចនោះគំគួនចង់សម្លាប់លោកយមរាជណាស់។ មន្ត្រីនោះមានស្រីបម្រើម្នាក់ជាទីទុកចិត្ត។ ស្រីបម្រើនោះខំផ្តាប់ផ្តុនចៅហ្វាយមិនឱ្យទាស់ចិត្ត។ វេលាយប់ស្ងាត់មន្ត្រីនោះនិយាយនឹងស្រីបម្រើថា "យើងចង់ឱ្យនាងជួយខ្ញុំរឿងមួយ ព្រោះយើងស្អប់លោកយមរាជនោះណាស់ យើងចង់សម្លាប់គេចោលតែមិនដឹង

រកអ្នកណាឱ្យជួយបាន តែសព្វថ្ងៃយើងឃើញនាងមានប្រាជ្ញាជាងគេ"។ ហើយ មន្ត្រីនោះបង្គាប់ស្រីបម្រើថា "ចូរឯងចេញពីខ្ញុំហើយទៅរកប្រាក់លោកយមរាជ ហើយនាងនៅនឹងគេសិនចុះ តែឯងត្រូវខំផ្គាប់ផ្គុនគេឱ្យដូចជានៅនឹងយើង ពេលលោកយមរាជនោះទុកចិត្តនឹងនាងឱ្យនាងចូលទៅបម្រើខាងក្នុង នាងចាំ មើលវេលាស្ងាត់ពេលលោកយមរាជដេកលក់ ចូរនាងដុតរំលាយសំណឱ្យពុះក្តៅ រួចយកទៅចាក់ក្នុងមាត់លោកយមរាជនោះទៅ គេនឹងស្លាប់គ្មានអ្នកណាដឹង ឡើយ បើឯងធ្វើបែបនេះបាន យើងនឹងចេញប្រាក់លោះនាងយកមកវិញឱ្យរួចពី ខ្ញុំគេ។ ស្រីបម្រើនោះស្តាប់ហើយក៏ទទួលការសព្វគ្រប់។

That time a minister of justice and a low ranking official had disputed for months. The low ranking official intended to kill the minister. He had an honest maid, who was very good at serving her master.

In the quiet night the official talked to his maid, "I need your favor. I am full of hatred for the minister and want to assassinate him. I do not have anyone to help me but you. I've discovered that you're the cleverest among the others."

"Leave me to work for that minister," ordered the official. "Try to serve him best as what you have done to me. After the minister trusts you and he will permit you to work indoor, at a time of quiet when he is deeply asleep, pour some boiling lead into his mouth. He must be boiled to death and no one knows how he is killed. And if the scheme is successful, I'll pay to free you from slavery." The maid listened and took her master's order.



នៅក្នុងវេលាយប់នោះដែរ **ចោរចិត្តថា** ដើរលួចគេហើយក៏មកអង្គុយក្រោមផ្ទះមន្ត្រីនោះ កាលមន្ត្រីបង្គាប់ស្រីបម្រើឱ្យសម្លាប់លោកយមរាជដូចម្តេចក៏ស្តាប់បានទាំងអស់។ ថ្ងៃក្រោយស្រីបម្រើនោះលាម្ចាស់ទៅរកប្រាក់លោកយមរាជហើយនៅបម្រើលោកយមរាជៗក៏ទទួលចេញប្រាក់លោះឱ្យនៅបម្រើខ្លួន។ នាងនោះផ្គាប់ផ្គុនខំបម្រើលោកយមរាជនិងលោកជំទាវមិនឱ្យទាស់ចិត្តឡើយ។ លោកយមរាជនិងលោកជំទាវក៏ទុកចិត្តស្និទ្ធស្នាលឱ្យនាងចេញចូលខាងក្នុងបម្រើជិតដិតធម្មតា។


That night, Chor Chitchea stole the other people and went to sit under the official's house. He heard every word the official spoke to his maid. Later, the maid left the official to borrow some money from the minister and asked to work for him. The minister bought her back in order to serve him. She tried her best to serve the minister and his wife that they had never been upset. The minister and his wife trusted her and let her serve them closely inside the house ever since.



នៅវេលាយប់ស្ងាត់ស្រីបម្រើនោះដឹងថា លោកយមរាជសម្រាន្តលក់ហើយនាងក៏ដុតរំលាយសំណឱ្យពុះក្តៅ ហើយលើកសំណនោះទៅចាក់ចូលក្នុងមាត់លោកយមរាជ។ ក៏ស្លាប់បាត់ទៅ រួចនាងនោះក៏ត្រឡប់ទៅកន្លែងដេកវិញ។ លុះព្រឹកឡើងលោកជំទាវក៏ភ្ញាក់បានដឹងថាប្តីស្លាប់ក៏ស្រែកទ្រហោយំធ្វើឱ្យមនុស្សផ្អើលមកមើល។ លោកជំទាវក៏ទៅក្រាបបង្គំទូលស្តេចតាមដំណើររឿង។ ព្រះរាជាក៏ទ្រង់ចាត់មន្ត្រីឱ្យមកមើលតែមិនដឹងថាគេស្លាប់ដោយសារអ្វីព្រោះគ្មានស្លាកស្នាម ក៏ទៅក្រាបបង្គំទូលស្តេចតាមដំណើររឿង។ ព្រះរាជាទ្រង់ឱ្យគេយកសពយមរាជទៅបញ្ចុះតាមការគួរ។

In the middle night, this servant discovered that the minister of justice was asleep; she started to melt the lead in its hot temperature, and poured it into the mouth of minister then he was boiled to death, and she went back to sleep. In the next morning, the minister's wife got up knowing that her husband was dead, she cried loudly making the people came around to see her. She went to tell the king what happened to her husband. And the king, after that, ordered his men to bury the corpse accordingly.

ក្រោយមកដល់រដូវបុណ្យទ្វាទសមាស នាម៉ឺនសព្វមុខមន្ត្រីចូលគាល់ព្រះមហាក្សត្រៗទ្រង់មានព្រះរាជឱង្ការថា "បើអ្នកណារកមនុស្សដែលសម្លាប់លោកយមរាជឃើញយើងនឹងឱ្យធ្វើជាទីយមរាជ" រួចមកស្តេចក៏យាងចូលខាងក្នុងវិញ។ សេនាបតីនាម៉ឺនសព្វមុខមន្ត្រីក៏ទៅផ្ទះរៀងៗខ្លួន។ គ្រានោះចៅហ្វាយស្រុកដែលជាសម្លាញ់នឹង **ចោរចិត្តជា** ចង់ធ្វើយមរាជណាស់បានទៅរក **ចោរចិត្តជាៗ** សួរថា "សម្លាញ់ឯងមកមានការអ្វី?" ចៅហ្វាយស្រុកប្រាប់ថា "ខ្ញុំមកមានការចង់សួរឯងបន្តិចត្បិតលោកយមរាជស្លាប់ដោយឥតមាននរណាដឹងថាស្លាប់ពីរោគអ្វី ឥឡូវស្តេចមានព្រះរាជឱង្ការថា



"បើអ្នកណារកឃើញមនុស្សដែលសម្លាប់លោកយមរាជឃើញ ទ្រង់នឹងឱ្យធ្វើជាទីយមរាជ រឿងនេះសម្លាញ់ឯងដឹងឬទេ? ត្បិតខ្ញុំចង់ធ្វើយមរាជណាស់"។ **ចោរចិត្តជា** ឆ្លើយថា "រឿងនេះខ្ញុំបានដឹងច្បាស់ ព្រោះនៅយប់មួយនោះ ខ្ញុំដើរលួចគេហើយខ្ញុំមកអង្គុយក្រោមផ្ទះមន្ត្រីតូចម្នាក់នៅខាងជើងផ្ទះលោកយមរាជឆ្ងាយពីគ្នាបន្តិច មន្ត្រីនោះបាននិយាយប្រាប់ស្រីបម្រើម្នាក់។ **ចោរចិត្តជា** ក៏និយាយតាមដំណើររឿងគ្រប់យ៉ាង។ **ចោរចិត្តជា** បានប្រាប់ថា "ចូរសម្លាញ់ឯងទៅក្រាបទូលស្តេចតាមរឿងនេះចុះ តែឱ្យគាស់ខ្មោចលោកយមរាជនោះមកវះមើល បើឃើញសំណនៅក្នុងពោះនោះមែន សម្លាញ់ឯងនឹងបានធ្វើជាយមរាជមិនខាន"។ ចៅហ្វាយស្រុកស្តាប់បានការហើយក៏ត្រឡប់ទៅផ្ទះវិញ។

Later, when it was the great ceremony, all officials went to see the king. "If anyone is possible to find the murder of the minister of justice, I will allow him to replace his function", said the king and went back inside after his proclamation. All officials returned their homes respectively. Meanwhile, the district governor, who was a friend of the generous thief, had strong desire to take that position. He, therefore, went to see the generous thief. "My dear friend, what are you looking for?" asked the generous thief. And the governor told him, "I want to ask you about the death of minister of justice who was secretly killed and no one has known what caused him to death." Now the king said, "If anyone can find who killed the minister, he will appoint that person to take the position of the minister of justice instead, have you known this matter? As I am desperately anxious to be a person in charge of that position. The generous thief replied, "I have known this matter clearly, because that night after stealing the people, I sat under the house of a low ranking official, just not far from the north of the minister of justice's house, hearing that official talk to a servant." And the generous thief narrated all the account of story to his friend. The thief said, "Please tell this story to the king, and ask for the permission to dig up the corpse. If the lead is found inside the dead body's belly, you will be appointed as the minister of justice eventually," added the generous thief. The district governor returned home happily after he had listened to the story.

ថ្ងៃក្រោយចៅហ្វាយស្រុកទៅទូលស្តេចតាមរឿងពិតគ្រប់យ៉ាង ស្តេចទ្រង់ឱ្យ
ភ្ជាក់ងារទៅចាប់មន្ត្រី និងស្រីបម្រើនោះមកឃុំទុក ទ្រង់ឱ្យគាស់ខ្ពោចលោក
យមរាជមកវះមើលឃើញសំណនៅក្នុងពោះមែន ទ្រង់ឱ្យជំនុំជំរះរឿងនោះ ស្រី
បម្រើបានសារភាពថា "មែន"។ ទើបស្តេចឱ្យគេប្រហារជីវិតទាំងពីរនាក់ចោល
ទៅ។ ទ្រង់ក៏តាំងចៅហ្វាយស្រុកនោះឱ្យធ្វើទីយមរាជ។



Later day, the district governor went to tell the story to the king; there he ordered his servants to arrest that official and his maid servant. After that he ordered to have the corpse dug up and cut open the belly; then the lead was really found inside the dead body. The king ordered to have a hearing, and the maid servant confessed that she really killed the minister. Therefore, the king sentenced both of them into death, and then he appointed the district governor as the minister of justice ever since.

ឯចៅហ្វាយស្រុក កាលបើបានធ្វើទីយមរាជហើយក៏ឱ្យអ្នកបម្រើទៅហៅ **ចោរចិត្តជា** ជាសម្លាញ់។ លុះមកដល់គាត់ក៏ប្រាប់ថា "សម្លាញ់អើយ! ឯងមានគុណលើខ្ញុំច្រើនណាស់ ឥឡូវនេះខ្ញុំបានធ្វើជាយមរាជគឺដោយសារតែឯងជួយខ្ញុំ ពីថ្ងៃនេះតទៅ ចូរឯងកុំលួចគេទៀត ខ្ញុំសុខចិត្តចិញ្ចឹមម្តាយឯង និងសម្លាញ់ឯងអស់មួយជីវិត"។ **ចោរចិត្តជា** ឆ្លើយថា "ខ្ញុំសុំលួចតែម្តងទៀតទេ" និយាយរួច **ចោរចិត្តជា** ក៏ត្រឡប់ទៅផ្ទះវិញ។ វេលាយប់ **ចោរចិត្តជា** ទៅលួចដង្ហៅម្នាក់បានប្រាក់និងសំពត់អាវជាច្រើនយកទៅជូនម្តាយ។



Since the district governor was appointed as the minister of justice, he ordered his servant to invite the generous thief, his friend to see him. The generous thief arrived as invited by minister, he suddenly said, "My dear friend! you have done me a lot of favors; I nowadays became the minister of justice, because of your assistance. So you should abandon stealing other people's properties from now on, and I pledge to support you and your mother for whole life." "I would steal once", replied the generous thief, and went back to his house. At night, he went to steal a merchant from whom he had collected much money and a lot of clothes for his mother.



លុះព្រឹកឡើង **ចោរចិត្តជា** មកប្រាប់លោកយមរាជថា "សម្លាញ់! យប់មុិញខ្ញុំលួចគេបានប្រាក់ និងសំពត់អាវច្រើនណាស់ ពីថ្ងៃនេះតទៅខ្ញុំលះបង់លែងរកស៊ីលួចគេទៀតហើយ សូមសម្លាញ់ជឿខ្ញុំចុះ"។ លោកយមរាជតបថា "បើឯងឈប់លួចគេមែននោះខ្ញុំអរណាស់ បើខ្វះខាតអ្វីមករកខ្ញុំចុះ ឯងកុំទើសទាល់អី ខ្ញុំធានាចិញ្ចឹមឯងអស់មួយជីវិត។ **ចោរចិត្តជា** ក៏លាលោកយមរាជទៅផ្ទះវិញទៅនៅថែរក្សាមាតាជាសុខសប្បាយ។ លោកយមរាជ និង **ចោរចិត្តជា** ស្រឡាញ់រាប់អានគ្នាចិញ្ចឹមគ្នាដរាបអស់ជីវិតដូចបានសន្យានឹងគ្នា។ **ចប់**

មនុស្សចិត្តជាតែងមានគ្នាគិតឥ

In the morning, the generous thief went to tell the minister, "Dear friend! Last night I stole the money and a lot of clothes. Please believe me; I will abandon my job of stealing from now on." The minister replied, "I am very cheerful that you decided to drop out of such a job. You can come to me at any time if you are in the shortage, and I ensure to support you for your whole life." The generous thief, after all, left the minister and lived happily with his mother. And they both became closed friends, who supported each other as their promise. **The End**

The generous person is always supported.